# បទបញ្ជាដំណើរការ
# សេវាសម្រាប់បម្រើក្រុមគ្រួសារសិស្ស (SAF)

## មាត្រា ១ ៖ លក្ខខណ្ឌទូទៅក្នុងការទទួលសិស្ស

- **<u>សកម្មភាពក្រៅម៉ោងសិក្សា</u>** (AES)

សម្រាប់សិស្សានុសិស្សចាប់ពីថ្នាក់មត្តេយ្យ ដល់ថ្នាក់មធ្យមសិក្សា។ គោលបំណងចំបងរបស់ AES គឺដើម្បីឱ្យសិស្សានុសិស្សរបស់សាលាអាចរៀន ឬហ្វឹកហាត់បង្កើនសកម្មភាពកីឡា វប្បធម៌ ឬសកម្មភាពសប្បាយៗនៅក្នុងបរិយាកាសកម្សាន្តលំហែ។ ចំនួនកន្លែងមានកំណត់ ដោយមូលហេតុការគ្រប់គ្រង និងសុវត្ថិភាព។

- **<u>ជំនួយក្នុងការធ្វើកិច្ចការ</u>** (AAD)

សម្រាប់សិស្សានុសិស្សចាប់ពីថ្នាក់បឋមសិក្សា ដល់ថ្នាក់អនុវិទ្យាល័យ។ យើងខ្ញុំផ្ដល់ជូនកន្លែងធ្វើកិច្ចការស្ងាត់ស្ងៀម (អ្នកទទួលបន្ទុកម្នាក់មានសិស្សយ៉ាងច្រើនបំផុតត្រឹម ៨នាក់)។ **ជំនួយក្នុងការធ្វើកិច្ចការ មិនមែនជាការបង្រៀនបំប៉នផ្ទាល់ខ្លួននោះទេ។**

- **<u>ការមើលថែក្មេង</u>** (GDR)

សម្រាប់សិស្សានុសិស្សថ្នាក់ CP ដល់ថ្នាក់ CM2 បន្ទាប់ពីចប់ម៉ោងសិក្សារហូតដល់ម៉ោង ៦ល្ងាច។ ការចុះឈ្មោះគិតតាមចំនួនម៉ោងក្នុងរយៈពេលមួយឆមាស។ កុមារដែលមាតាបិតាមកទទួលយឺតពេល នឹងត្រូវគិតថ្លៃសេវា ១ម៉ោង បន្ថែមដោយស្វ័យប្រវត្តិ។ ប្រសិនការយឺតយ៉ាវនៅតែមានបន្ត កុមាររូបនោះនឹងមិនត្រូវបានទទួលមកកន្លែងមើលថែក្មេងទៀតទេ រហូតដល់ចប់ឆ្នាំសិក្សា។

- **<u>សេវាផ្នែកអាហារដ្ឋានសាលា</u>** (SRS)

សម្រាប់សិស្សានុសិស្សគ្រប់រូបដែលបានចុះឈ្មោះ រយៈពេល**១ត្រីមាស**ម្ដង។ អ្នកទទួលបន្ទុកផ្នែក និងក្រុមការងាររបស់ការិយាល័យ Vie Scolaire ត្រួតពិនិត្យ និងនាំសិស្សក្មេងៗទៅបរិភោគអាហារ។ សម្រាប់សិស្សថ្នាក់មត្តេយ្យ និងថ្នាក់បឋមសិក្សា មានសកម្មភាពខ្លីៗ ត្រូវបានស្នើឱ្យធ្វើ បន្ទាប់ពីទទួលទានអាហាររួច។ សកម្មភាពទាំងនោះត្រូវបានមើលការខុសត្រូវដោយអ្នកទទួលបន្ទុកសកម្មភាពតាមផ្នែកនីមួយៗ។

## មាត្រា២ : ការចុះឈ្មោះ

- **<u>លក្ខខណ្ឌនៃការចុះឈ្មោះ</u>**

ការចុះឈ្មោះធ្វើឡើង ៖

- ១ ឆមាសម្ដង សម្រាប់ AES/AAD និងសេវាមើលថែក្មេង
- ១ ត្រីមាសម្ដង សម្រាប់សេវាកម្មអាហារដ្ឋានសាលា

**បទបញ្ញាដំណើរការ**
**សេវាសម្រាប់បម្រើក្រុមគ្រួសារសិស្ស** (SAF)

មាតាបិតាសិស្សគ្រប់រូប នឹងត្រូវបានជូនដំណឹងជាមុននាអំឡុងពេលធ្វើការចុះឈ្មោះ។ ការចុះឈ្មោះនេះមានរយៈពេលជាច្រើនថ្ងៃ។ ក្រោយរយៈពេលនេះ ការចុះឈ្មោះអាចធ្វើទៅបាន តែក្នុងករណីពិសេសណាមួយ ឬតាមការស្នើសុំរបស់ផ្នែករដ្ឋបាល LFRD។ ការចុះឈ្មោះនីមួយៗ ត្រូវបានកំណត់ដោយ SAF ត្រូវបង់ប្រាក់ជាមុន មិនអាចទារសំណងវិញ និងត្រូវគោរពតាមបទប្បញ្ញត្តិហិរញ្ញវត្ថុ។

- សុពលភាពនៃការចុះឈ្មោះ

**មានតែការចុះឈ្មោះ ដែលបានធ្វើឡើងក្នុងរយៈពេលកំណត់ប៉ុណ្ណោះ ដែលមានសុពលភាព។** ក្នុងករណីដែលមិនបានបង់ប្រាក់លើថ្លៃសេវាណាមួយកាលពីឆ្នាំសិក្សាមុន ឬសេវាណាមួយមុនពេលការចុះឈ្មោះបច្ចុប្បន្ន នោះកូនលោកអ្នកនឹងមិនត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះធ្វើសកម្មភាព ឬទទួលសេវាណាមួយនោះទេ។

សម្រាប់ការចុះឈ្មោះធ្វើសកម្មភាពមួយចំនួន គឺយើងខ្ញុំតម្រូវឱ្យមានការស្នើសុំពីសំណាក់គ្រូបង្រៀន បន្ទាប់ពីបានធ្វើការសាកល្បង។ ឧទាហរណ៍ ៖ ហែលទឹក កាយសម្ព័ន្ធ ការប្រកួត ...

## មាត្រា៣ : ការត្រួតពិនិត្យ

ក្រុមការងារផ្នែកសេវានីមួយៗ រួមមានអ្នកទទួលបន្ទុកមកពីខាងក្រៅសាលា ឬរបស់សាលា គឺស្ថិតក្រោមការទទួលខុសត្រូវរបស់ប្រធានផ្នែកសេវាសម្រាប់បម្រើគ្រួសារសិស្ស។ ពួកគេទទួលបន្ទុកលើការដឹកនាំ និងដំណើរការរបស់សកម្មភាពនីមួយៗ។ ពួកគេធានានូវសុវត្ថិភាពផ្នែករាងកាយ និងផ្នែកសតិអារម្មណ៍របស់សិស្សានុសិស្ស។

## មាត្រា៤ : ការអវត្តមានអ្នកទទួលបន្ទុកសកម្មភាព

សិស្សក្មេងៗស្ថិតក្រោមការទទួលខុសត្រូវរបស់ SAF។ នៅពេលចប់ការលេងសកម្មភាពនីមួយៗ អ្នកទទួលបន្ទុកសកម្មភាពនោះ នឹងនាំសិស្សយកទៅកន្លែងមើលថែក្មេង។ មានក្រដាសស្រង់វត្តមានមួយត្រូវបំពេញសម្រាប់គ្រប់វគ្គសកម្មភាពទាំងអស់។ តាមដែលអាចធ្វើទៅបាន ប្រសិនបើមានរឿងអ្វីមិនប្រក្រតី យើងខ្ញុំនឹងជូនព័ត៌មានទៅក្រុមគ្រួសារទុកជាមុន។

ក្នុងករណីអ្នកទទួលបន្ទុកសកម្មភាពអវត្តមាន យើងខ្ញុំមានដំណោះស្រាយ២ខាងក្រោម ៖

- យើងខ្ញុំមានមនុស្សមកជំនួសអ្នកទទួលបន្ទុកសកម្មភាពអវត្តមាននោះ ដើម្បីនាំសិស្សលេងសកម្មភាពដែលពួកគេបានចុះឈ្មោះ។
- សិស្សថ្នាក់មត្តេយ្យ និងថ្នាក់បឋមសិក្សាត្រូវបាននាំមកកន្លែងមើលថែក្មេង រីឯសិស្សថ្នាក់មធ្យមសិក្សាគឺស្ថិតក្រោមការទទួលខុសត្រូវរបស់បុគ្គលិកការិយាល័យ Vie Scolaire។

## មាត្រា៥ : ការអវត្តមានសិស្ស

ក្នុងករណីអវត្តមានម្តងម្កាល ឬរយៈយូរ សម្រាប់សេវាផ្នែកអាហារដ្ឋាន ឬក្នុងការចូលរួមលេងសកម្មភាពមួយ ឬច្រើន វាចាំបាច់ក្នុងការប្រាប់ដំណឹងមក SAF តាមរយៈអ៊ីម៉ែល safe@lfrd.net ឬតាមទូរសព្ទលេខ ០២៣ ៧២២ ៣៣១ (Rattana UN) ឬ ០៦១ ៨០៥ ៨៣២ (Hélène SA IM) ។

## មាត្រា៦ : សម្លៀកបំពាក់ និងសម្ភារៈ

ដើម្បីឱ្យសិស្សានុសិស្សចូលរួមដោយរលូនក្នុងកំឡុងពេលធ្វើសកម្មភាពកីឡា យើងខ្ញុំស្នើសុំឱ្យក្រុមគ្រួសារផ្តល់សម្លៀកបំពាក់ដែលសម្របទៅនឹងសកម្មភាពនោះដល់ពួកគាត់។ សម្រាប់សកម្មភាព និងការចេញដំណើរទៅក្រៅសាលា មួក និងដបទឹក គឺតម្រូវឱ្យមានជាចាំបាច់។
សម្រាប់សកម្មភាពខ្លះ សម្ភារៈជាក់លាក់មួយចំនួនតម្រូវឱ្យមាន។ ប្រសិនបើមានករណីនេះ ក្រុមការងារ SAF នឹងជូនដំណឹងដល់លោកអ្នកមុនពេលចាប់ផ្តើមសកម្មភាពទាំងនោះ។

## មាត្រា៧ : ការគោរពអ្នកដទៃ និងសម្ភារៈ

អ្នកដែលចូលរួមធ្វើសកម្មភាពគ្រប់រូបត្រូវគោរពគោលការណ៍នៃបទបញ្ជាផ្ទៃក្នុង។ អ្នកចូលរួមគ្រប់រូបត្រូវគោរពគំនិត និងមនុស្សដែលមានវត្តមាន។ រាល់អំពើហឹង្សាលើរាងកាយ ឬការបំពានដោយពាក្យសម្តីនឹងត្រូវទទួលទោស។
អ្នកដែលចូលរួមធ្វើសកម្មភាពគ្រប់រូបត្រូវគោរពសម្ភារៈដែលបានផ្តល់ឱ្យ។ រាល់ការលួច ឬការធ្វើឱ្យខូចខាតសម្ភារៈនឹងត្រូវទទួលទោស។
សិស្សានុសិស្សណាដែលមិនគោរពបទបញ្ជាជារឿយៗ អាចនឹងត្រូវបញ្ឈប់ពីការលេងសកម្មភាពនោះ (សំណងជាប្រាក់គិតទៅតាមចំនួនម៉ោងដែលនៅសល់) ។

## មាត្រា ៨: តម្លៃ ការទូទាត់ប្រាក់ និងសំណង

តម្លៃទាំងអស់មានបញ្ជាក់នៅលើគេហទំព័ររបស់យើង។ លោកអ្នកនឹងទទួលវិក័យប័ត្រសរុបមួយ សម្រាប់ការចុះឈ្មោះលើសេវាដែលបានជ្រើសរើស។ តាមដែលអាចធ្វើទៅបាន យើងខ្ញុំនឹងជូនដំណឹងដល់លោកអ្នកជាមុនពីរយៈពេលទូទាត់ប្រាក់។

ការមើលថែក្មេងនឹងគិតថ្លៃសេវា ១ម៉ោងបន្ថែម សម្រាប់ការមកទទួលសិស្សយឺតលើសពី ១៥ នាទី។
ការមើលថែក្មេង ១ម៉ោង មុន ឬបន្ទាប់ពីការលេងសកម្មភាពក្រៅម៉ោងសិក្សា គឺត្រូវបានគិតថ្លៃសេវា។

គ្មានសំណង ជាអាហារសម្រាប់សេវាផ្នែកអាហារដ្ឋាន ឬសំណងជាសកម្មភាពសម្រាប់សេវា AES ឬសំណងការមើលថែសម្រាប់សេវាមើលថែក្មេង ក្នុងកំឡុងពេលឆមាសនោះទេ បើសិនក្នុងករណីមានអាកាសធាតុមិនល្អ ឬសិស្សអវត្តមាន ឬសិស្សឈប់ធ្វើសកម្មភាព ឬការលុបចោលជាលក្ខណៈពិសេសនៃសកម្មភាពណាមួយ។

មានតែករណី៤ខាងក្រោមប៉ុណ្ណោះ ដែលអាចត្រូវបានសងប្រាក់មួយចំនួនវិញ ៖

- ការឈប់រៀនពីសាលា។
- អវត្តមានរយៈពេលយូរ ដោយសារជំងឺ ឬបញ្ហាវេជ្ជសាស្ត្រណាមួយ ដែលអសមត្ថភាពបន្តលេងសកម្មភាពរហូតដល់ចប់ឆមាស។ ក្នុងករណីនេះ យើងខ្ញុំទាមទារឱ្យក្រុមគ្រួសារមានសំបុត្រពេទ្យយកមកបញ្ជាក់។
- ការលប់ចោលសកម្មភាពច្រើនជាង ៣ ដង ដែលធ្វើឡើងដោយ LFRD។
- ការបញ្ឈប់សិស្សពីការចូលរួមសកម្មភាពណាមួយ។

ក្នុងករណីជាក់លាក់ទាំងនេះ សំណងនឹងត្រូវបានទូទាត់ស្របតាមចំនួនវគ្គសកម្មភាពដែលបានធ្វើ ឬតាមចំនួនអាហារដែលបានបរិភោគ។

## មាត្រា៩ : ការធានារ៉ាប់រង

សាលាបានចុះឈ្មោះទទួលសេវាធានារ៉ាប់រង។ សេវានេះធានា លើការគ្រោះថ្នាក់ដល់សិស្សក្នុងម៉ោងសិក្សា និងក្រៅម៉ោងសិក្សា ក្នុងករណីការចូលរួមធ្វើសកម្មភាព AES។ ព័ត៌មានលម្អិតនៃការធានារ៉ាប់រងអាចរកបានតាមរយៈការស្នើសុំពីផ្នែកហិរញ្ញវត្ថុរបស់សាលា។ ក្រុមគ្រួសារអាចនឹងចុះឈ្មោះទទួលសេវាធានារ៉ាប់រងជាលក្ខណៈឯកជន និងបុគ្គលបន្ថែមបាន ដើម្បីបង្កើនការធានាឱ្យកាន់តែទូលំទូលាយ។

## មាត្រា១០ : ការលុបចោលការចុះឈ្មោះ

ក្នុងករណីដែលមិនគោរពតាមបទបញ្ជានេះ សាលាសូមរក្សាសិទ្ធិក្នុងការលុបចោលការចុះឈ្មោះសិស្សក្នុងការចូលរួមសកម្មភាពណាមួយ។